**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**
**លេខ៖ ថក ២២/២០២៥ កបទ.សអ**

# សេចក្តីថ្លែងការណ៍របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នៃព្រះរាជាណាចក្រកម្ពុជា

ព្រះរាជាណាចក្រកម្ពុជាសូមស្វាគមន៍ចំពោះកិច្ចព្រមព្រៀងសន្តិភាពនៅតំបន់ហ្គាហ្សា ដែលបានចុះហត្ថលេខានៅថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២៥ នៅប្រទេសអេហ្ស៊ីប **ដោយ ឯកឧត្តម ដូណាល់ ត្រាំ** ប្រធានាធិបតីនៃសហរដ្ឋអាម៉េរិក **ឯកឧត្តម អាប់ដែល ហ្វាតា អ៊ែល-ស៊ីស៊ី** ប្រធានាធិបតី នៃសាធារណរដ្ឋអារ៉ាប់អេហ្ស៊ីប **ព្រះអង្គម្ចាស់ តាមីម ពិន ហាម៉ាត់ អាល់-ថានី** ព្រះចៅនៃរដ្ឋកាតា និង**ឯកឧត្តម រ៉ីស៊ីប តាយយ៉ីប អ៊ែរដូហ្គាន់** ប្រធានាធិបតីនៃសាធារណរដ្ឋតួកគីយ៉េ។

កម្ពុជាសូមកោតសរសើរដល់ការដឹកនាំរបស់ឯកឧត្តម ដូណាល់ ត្រាំ ប្រធានាធិបតីសហរដ្ឋអាម៉េរិក និងអ្នកសម្របសម្រួលទាំងអស់ ចំពោះការខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្លាក្នុងការសម្រេចបាននូវលទ្ធផលនេះ និងសង្ឃឹមថា កិច្ចព្រមព្រៀងសន្តិភាពនេះនឹងត្រួសត្រាយផ្លូវសម្រាប់សន្តិភាពយូរអង្វែង និងការវិលត្រឡប់ទៅរកប្រក្រតីភាពឡើងវិញសម្រាប់ភាគីទាំងពីរ។

កម្ពុជាសូមបញ្ជាក់សាជាថ្មីនូវការគាំទ្រចំពោះដំណោះស្រាយរដ្ឋពីរ និងលើកទឹកចិត្តគ្រប់ភាគីឱ្យបន្តការសន្ទនាស្របតាមសេចក្តីសម្រេចពាក់ព័ន្ធនានារបស់អង្គការសហប្រជាជាតិ និងច្បាប់អន្តរជាតិ៕

ថ្ងៃសុក្រ ១០រោច ខែអស្សុជ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែតុលា ឆ្នាំ២០២៥

អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីម៉ែល: mfaic@mfaic.gov.kh

*Unofficial Translation*

No. SM 22 /2025 MFA.IC

## Statement of the Ministry of Foreign Affairs and International Cooperation of the Kingdom of Cambodia

The Kingdom of Cambodia welcomes the Peace Agreement in Gaza, signed on 13 October 2025 in Egypt, by **President Donald J. Trump** of the United States of America, **President Abdel Fattah El-Sisi** of the Arab Republic of Egypt, **Emir Tamim bin Hamad Al-Thani** of the State of Qatar, and **President Recep Tayyip Erdoğan** of the Republic of Türkiye.

Cambodia commends the leadership of U.S. President Donald Trump and all mediators for their tireless efforts in achieving this outcome and hopes the Peace Agreement will pave the way for a lasting peace and a return to normalcy for both sides.

Cambodia reaffirms its support for the two-state solution and encourages all parties to pursue dialogue in line with relevant UN resolutions and international law.

Phnom Penh, 17 October 2025